# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃអង្គារ ៣កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៥

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម៖**

១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និង អង្គការពាក់ព័ន្ធដែលចូលរួមផ្ទាល់ចំនួន៣៧រូប និងតាមប្រព័ន្ធអនឡាញចំនួន៣៥រូប សរុបចំនួន៧២រូប។

**៤. របៀបវារៈ៖**

១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

២- បទបង្ហាញស្តីពី និតិវិធីនៃការផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល ដល់បុគ្គលបម្រើ សេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ(ក្រុមប្រឈមមុខខ្ពស់)បង្ហាញដោយលោក **ឡាត់ ម៉ារ៉ា** អនុប្រធាននាយកដ្ឋានបញ្ជិកា និងភាគទាន។

៣-មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

សមាជិកសមាជិកានៃកិច្ចប្រជុំ និងបានលើកឡើងថា ប្រទេសកម្ពុជាបានសម្រេចលទ្ធផល ៩២-១០០-៩៨ ធៀបនឹងគោលដៅសាកល ៩៥-៩៥-៩៥។ ក្នុងចំណោមអ្នកសង្ស័យថាផ្ទុកមេរោគអេដស៍ទាំង៧៦០០០នាក់ មាន៧០០១៣នាក់ បានធ្វើតេស្តបញ្ជាក់ថាមានផ្ទុកHIV ស្មើនឹង៩២%។ ការឆ្លងថ្មី ១២០០នាក់ក្នុង១ឆ្នាំ ការស្លាប់ដោយសារមេរោគអេដស៍បានធ្លាក់ចុះមក១០០០នាក់ក្នុង១ឆ្នាំ។ ការឆ្លងថ្មីមេរោគអេដស៍ភាគច្រើនក្នុងចំណោមប្រជាជនគន្លឹះ (ដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ)ទាំងស្ត្រី បុរសរួមភេទជាមួយបុរស និងអ្នកបំប្លែងភេទ គ្រឹះស្ថានកម្សាន្ត និងសួនសាធារណៈចំនួនសរុបប្រមាណ ១៦ម៉ឺននាក់។ នាឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាសម្រេចផ្តល់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល (ម.ស.ស) ដល់ប្រជាជនគន្លឹះ ទាំងស្ត្រី បុរសរួមភេទជាមួយបុរស និងអ្នកបំប្លែងភេទ។ ការផ្តល់ប័ណ្ណ ម.ស.ស នេះជាឱកាសមួយគាំទ្រដល់ការងារឆ្លើយតបនឹងមេរោគអេដស៍ ហើយត្រូវបានដាក់វិធានការជាអាទិភាពមួយក្នុងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍។ និយាមប្រតិបត្តិចុះបញ្ជីផ្តល់ប័ណ្ណ ម.ស.ស នេះមានបំណងពន្លឿនការចុះបញ្ជីផ្តល់ប័ណ្ណ និងលើកទឹកចិត្តពួកគាត់មកធ្វើតេស្តឈាមរកមេរោគអេដស៍ និងទទួលបានសេវាថែទាំសុខភាពដទៃទៀត ពិសេសការព្យាបាលកាមរោគ ដោយប្រើប្រាស់ប័ណ្ណ ម.ស.ស។

លោក **ឡាត់ ម៉ារ៉ា** អនុប្រធាននាយកដ្ឋានបញ្ជិកា និងភាគទាន បានបង្ហាញពីនិតិវិធីនៃការផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល ដល់បុគ្គលបម្រើសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ៖

- វិសាលភាពនៃការគ្របដណ្តប់របបសន្តិសុខសង្គម
  - បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ គឺការគ្របដណ្តប់លើការផ្តល់ប័ណ្ណ ប.ស.ស សម្រាប់មន្ត្រីរាជការ។ ប័ណ្ណ ប.ស.ស បានផ្តល់លើ ហានិភ័យការងារ ផ្នែកថែទាំសុខភាព និងប្រាក់សោធន។
  - បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបញ្ញត្តិនៃច្បាប់ស្តីពីការងារដែលរួមបញ្ចូលទាំងបុគ្គលិកដែលធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបំរើក្នុងផ្ទះ។
  - បុគ្គលស្វ័យនិយោជន៍។
- នីតិវិធីនៃការផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល លក្ខខណ្ឌចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ៖
  - ដើម្បីចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធក្នុង ប.ស.ស សមាគមន៍ឬអង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតក្រៅប្រព័ន្ធទាំងអស់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

    - ចំពោះសមាគមន៍ត្រូវមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងមហាផ្ទៃ។

    - ចំពោះអង្គការវិជ្ជាជីវៈត្រូវមានវិញ្ញាណបនប័ត្រចុះបញ្ជីអង្គការវិជ្ជាជីវៈចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

- ចំពោះកម្មករនិយោជិតក្រៅប្រព័ន្ធដែលជាសមាជិករបស់សមាគមន៍ ឬអង្គការវិជ្ជាជីវៈត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ និងលិខិតបញ្ជាក់មុខរបរ និងទីលំនៅបច្ចុប្បន្នដែលទទួលស្គាល់ដោយអាជ្ញាធររាជធានីខេត្តតាមនីតិវិធី។

- និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានក្នុងសេវាកម្មទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវរៀបចំបញ្ជីឈ្មោះបុគ្គលបម្រើសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងសហគ្រសគ្រឹះស្ថានរបស់ខ្លួនទៅរដ្ឋបាលរាជធានី ខេត្ត ឬក្រុង ស្រុក។

➢ ចំនួនប័ណ្ណមូលនិធិសមធម៌សុខាភិបាល ដែលបានផ្តល់ជូនបុគ្គលបម្រើសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធសម្រាប់ឆ្នាំ២០២៥(គិតត្រឹមថ្ងៃទី២៥ខែសីហា ឆ្នាំ២០២៥)មាន ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តឧត្តរមានជ័យ ខេត្តស្វាយរៀង និងខេត្តកំពង់ធំ។

➢ បញ្ហាប្រឈមសម្រាប់បុគ្គលបម្រើសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធគឺ អត់មានអត្តសញ្ញាណប័ណ្ណដែលមិនអាចឱ្យគាត់ធ្វើអត្តសញ្ញាណប័ណ្ណបាន។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើង និងរកដំណោះស្រាយធ្វើយ៉ាងណា ដើម្បីឱ្យបុគ្គលបម្រើសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធទទួលបានប័ណ្ណ ម.ស.ស សម្រាប់យកទៅប្រើប្រាស់តាមតម្រូវការ។

ថ្ងៃចន្ទ ៩កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥

**បានពិនិត្យត្រឹមត្រូវ**

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**វេជ្ជ. ហួត សេរីរដ្ឋ**

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**

**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈឹម មិនឆារ៉េត**